ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 12-Jan-2015, 15:18
CMS/CFO: Sann Rada

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ** (ជាមួយឧបសម្ព័ន្ធសម្ងាត់មួយ)

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ការដាក់ជូនរបស់សហព្រះរាជអាជ្ញា នូវកំណត់ហេតុ និងប្រតិចារឹកក្នុងគោលបំណង ប្រើប្រាស់ជាភស្តុតាងសម្រាប់បញ្ជាក់អំពើ និងអាកប្បកិរិយា**

---

| អ្នកដាក់ឯកសារ: | អ្នកទទួលឯកសារ: | ចម្លងជូន: |
|---|---|---|
| **សហព្រះរាជអាជ្ញា** | **អង្គជំនុំជម្រះសាលាដំបូង** | **ជនជាប់ចោទ** |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Nicholas KOUMJIAN | ចៅក្រម Jean-Marc LAVERGNE | ខៀវ សំផន |
| | ចៅក្រម យ៉ា សុខន | |
| | ចៅក្រម Claudia FENZ | **មេធាវីការពារក្ដីជនជាប់ចោទ** |
| | ចៅក្រម យូរ ឧត្តារា | លោក សុន អរុណ |
| | | លោក Victor KOPPE |
| | **សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី** | លោក គង់ សំអុន |
| | លោក ពេជ អង្គ | លោកស្រី Anta GUISSÉ |
| | លោកស្រី Marie GUIRAUD | លោក Arthur VERCKEN |

# I. ចម្លើយតប

1. សហព្រះរាជអាជ្ញាឆ្លើយតបទៅនឹងសេចក្តីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤ ("ដីកាបង្គាប់") ដែលបានណែនាំឲ្យភាគីបញ្ជាក់ត្រឹមថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥ អំពីកំណត់ហេតុជាលាយលក្ខណ៍អក្សរ ឬប្រតិចារឹកដែលបានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសារដែលបានស្នើឡើងសម្រាប់សំណុំរឿង០០២/០២របស់ខ្លួន ដែលមានបំណងប្រើប្រាស់ជាភ័ស្តុតាងសម្រាប់បញ្ជាក់អំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ[1]។

2. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ជាទូទៅភ័ស្តុតាងដែលមានក្នុងកំណត់ហេតុ ឬប្រតិចារឹកបានពីការស្តាប់ចម្លើយសាក្សី ឬសក្ខីកម្មរបស់សាក្សីមុនៗដែលមានបញ្ជាក់អំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទនោះ "មិនអាចអនុញ្ញាតឲ្យយកមកប្រើប្រាស់តាមច្បាប់ឡើយ" អនុលោមតាមវិធាន៨៧(៣)(ឃ) នៃវិធានផ្ទៃក្នុង បើមិនបានផ្តល់ឱកាសឲ្យភាគីសួរដេញដោលសាក្សីរូបនោះនៅក្នុងតុលាការ[2]។ ការសម្រេចនេះមិនបានច្រានចោលការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងប្រតិចារឹកដែលពាក់ព័ន្ធ មានភ័ស្តុតាងបញ្ជាក់ពីបញ្ហាផ្សេងៗក្រៅពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ស្របតាមវិធាន៨៧(៣)ឡើយ និងប្រសិនបើមានប្រយោជន៍សម្រាប់យុត្តិធម៌ និងភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី គេត្រូវតែទទួលយកកំណត់ហេតុ និងប្រតិចារឹកទាំងនោះ[3]។ ការទទួលយកភ័ស្តុតាងដែលមានបញ្ជាក់អំពើ និងអាកប្បកិរិយាក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី ឬប្រតិចារឹកទាំងនោះ ក៏មិនបានច្រានចោលដែរ ប៉ុន្តែបើសិនជា "អវត្តមានពិតប្រាកដនៃឱកាសក្នុងការសួរដេញដោល"[4]ពិតមែន ដែលចំណុចនេះក៏ត្រូវរាប់បញ្ចូលទាំងការស្លាប់របស់បុគ្គលនោះ អសមត្ថភាពក្នុងការតាមរកបុគ្គលរូបនោះតាមការព្យាយាមយ៉ាងសមហេតុសមផល អសមត្ថភាពផ្នែកវេជ្ជសាស្ត្ររបស់បុគ្គលរូបនោះក្នុងការចូលមកបំភ្លឺដោយផ្ទាល់មាត់ និងភាពមិនអាចរកបានអាស្រ័យដោយការគំរាមកំហែង ការបំភិតបំភ័យ ឬឥទ្ធិពលមិនត្រឹមត្រូវផ្សេងៗ

---

[1] **E327** ការកំណត់កាលបរិច្ឆេទសម្រាប់សេចក្តីជំទាស់ទៅនឹងឯកសារផ្សេងៗទាក់ទងនឹងសំណុំរឿង០០២/០២, ១១ ធ្នូ ២០១៤។

[2] **E299** សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងភាពអាចទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រតិចារឹកនៅសំណុំរឿង០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី, ១៥ សីហា ២០១៣, កថាខណ្ឌ១៧។

[3] *ដដែលដូចខាងលើ*។

[4] *ដដែលដូចខាងលើ*, កថាខណ្ឌ១៨។

ទៀត[5]។ នៅក្នុងឯកសារដែលបានដាក់នេះ សហព្រះរាជអាជ្ញាកំណត់អត្តសញ្ញាណឯកសារដែលសហព្រះរាជអាជ្ញាចង់ពឹងផ្អែកជាភស្តុតាងសម្រាប់បញ្ជាក់អំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ គឺស្ថិតនៅក្នុងករណីលើកលែងនៃវិធានទូទៅនេះ។

3. ពាក្យថា "អំពើ និងអាកប្បកិរិយា" សម្រាប់គោលបំណងទាំងនេះ "អនុវត្តតែចំពោះកំណត់ហេតុស្តាប់ចម្លើយ ឬប្រតិចារឹកទាំងឡាយណា ដែលតាមលក្ខណៈរបស់វា បង្ហាញអំពើ និងអាកប្បកិរិយាផ្ទាល់ខ្លួនរបស់ជនជាប់ចោទដូចបានចោទប្រកាន់តែប៉ុណ្ណោះ"[6]។ លើសពីនេះ បទដ្ឋានខ្ពស់ស្តីពីភាពអាចទទួលយកបានដែលទាក់ទងទៅនឹងភស្តុតាងអំពីអំពើ និងអាកប្បកិរិយា អនុវត្តតែចំពោះកំណត់ហេតុស្តាប់ចម្លើយ ឬប្រតិចារឹកតែប៉ុណ្ណោះ ហើយមិនប៉ះពាល់ដល់ភាពអាចទទួលយកបាននៃភស្តុតាងដទៃទៀតឡើយ ដែលអនុលោមតាមវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង គឺគ្រាន់តែចាំបាច់ត្រូវមានភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន *ជាបឋម* ប៉ុណ្ណោះ[7]។

4. នៅក្នុងចម្លើយតបទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញាបានខំប្រឹងធ្វើការកំណត់អត្តសញ្ញាណលើកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកនានារបស់បុគ្គលទាំងឡាយ ដែលសហព្រះរាជអាជ្ញាបានដឹងថាមិនមានលទ្ធភាពអាចមកផ្តល់សក្ខីកម្មបាន ហើយដែលរួមមានភស្តុតាងបង្ហាញពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដែលភស្តុតាងទាំងនោះសហព្រះរាជអាជ្ញាមានបំណងត្រូវពឹងផ្អែកលើ។ ឯកសារទាំងនោះត្រូវបានកំណត់អត្តសញ្ញាណនៅក្នុង **ឧបសម្ពន្ធ ក** ដែលបានភ្ជាប់មកជាមួយ។ យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា នៅមុនការបញ្ចប់សំណុំរឿង០០២/០២ សហព្រះរាជអាជ្ញាអាចនឹងបានដឹងអំពីបុគ្គលនានាបន្ថែមទៀតដែលមិនមានលទ្ធភាពអាចមកផ្តល់សក្ខីកម្មបាន ហើយដែលកំណត់ហេតុស្តាប់ចម្លើយ និង/ឬ ប្រតិចារឹករបស់ពួកគាត់ មានភស្តុតាងអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដែលភស្តុតាងទាំងនោះ សហព្រះរាជអាជ្ញាមានបំណងត្រូវពឹងផ្អែកលើ។ ដូច្នេះសហព្រះរាជអាជ្ញារំពឹងទុកជាមុនថា អាចមានការចាំបាច់ត្រូវបំពេញបន្ថែមទៅក្នុងការដាក់ជូននេះនៅក្នុងអំឡុងពេលនៃដំណើរការលើសំណុំរឿង០០២/០២។

---

[5] *ដដែលដូចខាងលើ*, កថាខណ្ឌ១៧, ១៨។

[6] *ដដែលដូចខាងលើ*, កថាខណ្ឌ១៩ (សម្រង់ពាក្យផ្ទៃក្នុង ត្រូវបានរំលងចោល)។

[7] *ដដែលដូចខាងលើ*, កថាខណ្ឌ៣១។

## II. ដំណោះស្រាយដែលស្នើសុំ

5. ដូច្នេះ សហព្រះរាជអាជ្ញាស្នើដោយគោរព សូមឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកភស្តុតាងដែលបង្ហាញពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដែលមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី និងប្រតិចារឹកនានា ដូចដែលបានកំណត់អត្តសញ្ញាណនៅក្នុង **ឧបសម្ព័ន្ធ ក** ដែលបានភ្ជាប់មកជាមួយ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | | [signature] |